# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា
# សាលាបឋមសិក្សា George W Childs
# ច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា

## ផ្នែកទី១ ចំណងទូទៅ (គំរូដើម)

សាលានីមួយៗ នៅក្នុងច្បាប់ស្តីពីការចូលរួមរបស់មាតាបិតាទូទាំងសាលា ត្រូវបង្កើតឲ្យមានបំណងរបស់សាលា សម្រាប់ការចូលរួមរបស់មាតាបិតា។ *[មាត្រាលេខ១១១៨(a)(2) នៃច្បាប់ ESEA]*

សាលា George W Childs យល់ព្រមអនុវត្តតាមតម្រូវការនៃលក្ខន្តិកៈ ដូចតទៅ៖

- ក្រសួងអប់រំនឹងចាប់ផ្តើមប្រតិបត្តិនូវ កម្មវិធី សកម្មភាព និង វិធីផ្សេងៗ សម្រាប់ការចូលរួមរបស់មាតាបិតា នៅសាលាទាំងអស់របស់ក្រសួងអប់រំ ដែលទទួលជំនួយពីច្បាប់ Title I, Part A ដែលស្របតាមមាត្រាលេខ១១១៨ នៃច្បាប់អប់រំ សាលាបឋមសិក្សា និង មធ្យមសិក្សា (ESEA)។ កម្មវិធី សកម្មភាព និង វិធី ទាំងនោះ ត្រូវរៀបចំ និងធ្វើឡើងតាមការប្រឹក្សាដ៏មានអត្ថន័យជាមួយមាតាបិតារបស់ក្មេងដែលចូលរួម។

- តាមមាត្រាលេខ១១១៨ ក្រសួងអប់រំនឹងសហការជាមួយសាលាទាំងអស់របស់ក្រសួង ដើម្បីធ្វើយ៉ាងណាឲ្យច្បាប់ចូលរួមរបស់មាតាបិតានៅតាមសាលា ត្រូវតាមការតម្រូវរបស់មាត្រាលេខ១១១៨(b) នៃច្បាប់ ESEA ហើយការចូលរួមនីមួយៗ មានសមាសភាគ កិច្ចសន្យារវាងមាតាបិតា និង សាលា ស្របតាមមាត្រាលេខ១១១៨(d) នៃច្បាប់ ESEA។

- ក្រសួងអប់រំនឹងបញ្ចូលច្បាប់ស្តីពីការចូលរួមរបស់មាតាបិតាទូទាំងក្រសួងនេះទៅក្នុងផែនការរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា ដែលបង្កើតឡើងក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA។

- ក្នុងការអនុវត្តន៍ច្បាប់ Title I, Part A ការតម្រូវនៃការចូលរួមរបស់មាតាបិតា តាមតែអាចធ្វើទៅបាន ក្រសួងអប់រំ និងសាលាទាំងអស់ នឹងផ្តល់ឱកាសចូលរួមពេញលេញដល់ មាតាបិតាដែលចេះភាសាអង់គ្លេសតិចតួច មាតាបិតាដែលពិការ និង មាតាបិតារបស់ក្មេងដែលផ្លាស់ទីកន្លែងទៅតាមរដូវនៃការងាររបស់មាតាបិតា រួមទាំងការផ្តល់ព័ត៌មាន និងរបាយការណ៍សាលា ដែលបានតម្រូវដោយមាត្រាលេខ១១១១ នៃច្បាប់ ESEA តាមរបៀបដែលអាចយល់បាន និងតាមទ្រង់ដូចគ្នា រួមទាំងទម្រង់ផ្សេងទៀតទៅតាមការស្នើសុំ និងតាមការដែលអាចធ្វើទៅបាន ជាភាសាដែលមាតាបិតាអាចយល់បាន។

- បើសិនជាផែនការរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា សម្រាប់ច្បាប់ Title I, Part A ដែលបានបង្កើតឡើងក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA មិនពេញចិត្តមាតាបិតារបស់ក្មេងដែលចូលរួម ក្រសួងអប់រំនឹងបញ្ជូនយោបល់របស់មាតាបិតាជាមួយនឹងគម្រោងការនោះ នៅពេលក្រសួងអប់រំដាក់គម្រោងការនោះទៅក្រសួងអប់រំរដ្ឋ។

- ក្រសួងអប់រំនឹងឲ្យមានការចូលរួមពី មាតាបិតារបស់ក្មេងនៅសាលាដែលទទួលជំនួយពីច្បាប់ Title I, Part A ក្នុងការសម្រេចនូវការចំណាយប្រាក់ជំនួយ១ភាគរយនៃច្បាប់ Title I, Part A ដែលទុកចំណាយសម្រាប់ការចូលរួមរបស់មាតាបិតា ហើយនឹងធ្វើយ៉ាងណាមិនឲ្យតិចជាង៩៥ភាគរយ នៃប្រាក់ជំនួយ១ភាគរយនេះចំណាយទៅលើសាលា។

- និយមន័យនៃលក្ខន្តិកៈស្តីអំពីការចូលរួមរបស់មាតាបិតា នឹងត្រូវគ្រប់គ្រងមកលើក្រសួងអប់រំ ហើយសង្ឃឹមថា សាលាដែលទទួលជំនួយពីច្បាប់ Title I របស់ក្រសួងទាំងអស់នឹងបង្កើត កម្មវិធី សកម្មភាព និងវិធី ផ្សេងៗ ដែលស្របតាមនិយមន័យនេះ៖

*ការចូលរួមរបស់មាតាបិតាមានន័យថា ការចូលរួមរបស់មាតាបិតាជាធម្មតាគឺជាទំនាក់ទំនង ទៅវិញទៅមក និង មានអត្ថន័យ ដែលទាក់ទងដល់ការសិក្សារបស់សិស្សានុសិស្ស និងសកម្មភាពផ្សេងៗទៀតរបស់សាលា រួមទាំងការបញ្ជាក់ថា—*

*(ក) មាតាបិតាមានតួនាទីដ៏សំខាន់ ក្នុងការជួយដល់ការសិក្សារបស់កូន*

*(ខ) មាតាបិតាត្រូវទទួលការលើកទឹកចិត្តឲ្យចូលរួមយ៉ាងសកម្មក្នុងការសិក្សារបស់កូននៅសាលា*

*(គ) មាតាបិតាជាដៃគូយ៉ាងពេញទំហឹងក្នុងការសិក្សារបស់កូន និងតាមលក្ខណៈសមរម្យ ចូលរួមក្នុងការសម្រេចចិត្ត និងជាក្រុមប្រឹក្សា ដើម្បីជួយដល់ការសិក្សារបស់កូន*

*(ឃ) ធ្វើសកម្មភាពផ្សេងៗ ដូចជាអ្វីៗដែលបានរៀបរាប់ក្នុងមាត្រា១១១៨ នៃច្បាប់ ESEA។*

- ក្រសួងអប់រំនឹងជូនដំណឹងដល់មាតាបិតា និងអង្គការមាតាបិតា អំពីគោលបំណង និងផ្តល់ព័ត៌មានអំពីការចិញ្ចឹមបីបាច់កូន និង មណ្ឌលផ្តល់ជំនួយដែលមាននៅក្នុងរដ្ឋ។

## ផ្នែកទី២ ការរៀបរាប់អំពីវិធីដែលសាលានឹងអនុវត្តការតម្រូវនៃច្បាប់ចូលរួមរបស់មាតាបិតាទូទាំងក្រសួង

[**កំណត់សម្គាល់៖** ច្បាប់នៃការចូលរួមរបស់មាតាបិតាទូទាំងសាលា ត្រូវមានការរៀបរាប់អំពីវិធីដែលសាលានឹងអនុវត្ត ឬសម្រេចបាន នូវសមាសភាគនីមួយៗដូចតទៅ។ *[មាត្រាលេខ១១១៨(ខ)(2) នៃច្បាប់ ESEA]* ដោយមិនគិតពីទម្រង់ណាមួយដែលសាលាជ្រើសរើសប្រើ គឺត្រូវរួមបញ្ចូលការរៀបរាប់នៃសមាសភាគនីមួយៗខាងក្រោមនេះ ដើម្បីបំពេញតាមតម្រូវការនៃលក្ខន្តិកៈ។]

១. សាលា George W. Childs នឹងធ្វើសកម្មភាពដូចខាងក្រោមនេះ ដើម្បីឲ្យមាតាបិតាចូលរួមបង្កើតរួមគ្នា នូវផែនការនៃការចូលរួមរបស់មាតាបិតាទូទាំងសាលា ក្រោមមាត្រាលេខ១១១២ នៃច្បាប់ ESEA៖

គេបានផ្តល់ជូនមាតាបិតានូវលិខិតផ្សព្វផ្សាយ ថានឹងមានអង្គប្រជុំនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ នៅក្នុងបណ្ណាល័យរបស់សាលា ដើម្បីពិនិត្យមើលឡើងវិញនូវច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា។ សាលាបានធ្វើសារសម្លេងតាមទូរស័ព្ទ ទៅមាតាបិតាទាំងអស់ឲ្យដឹងអំពីអង្គប្រជុំនេះ។ សាលាបានផ្ញើអ៊ីមែលទៅបញ្ជីអ៊ីមែលរបស់មាតាបិតា នៅយប់មុនថ្ងៃប្រជុំ សុំមាតាបិតាអញ្ជើញមកចូលរួមប្រជុំ។ គ្រូបង្រៀនថ្នាក់ទីមួយ បានប្រគល់លិខិតរំឭកជូនដល់មាតាបិតាផ្ទាល់ មុនថ្ងៃប្រជុំមួយថ្ងៃ។ អង្គប្រជុំក៏មានចុះនៅក្នុងប្រតិទិនប្រចាំខែ ដែលបានផ្ញើទៅផ្ទះនៅ សប្តាហ៍ដំបូង នៃពេលដែលសាលាចាប់ផ្តើមបង្រៀន។

២. សាលា George W. Childs នឹងធ្វើសកម្មភាពដូចខាងក្រោមនេះ ដើម្បីឲ្យមាតាបិតាចូលរួមក្នុងវិធី ពិនិត្យ និង កែលម្អ សាលា ក្រោមមាត្រាលេខ១១១៦ នៃច្បាប់ ESEA៖

គេនឹងអញ្ជើញមាតាបិតាមកចូលរួមក្នុងអង្គប្រជុំ ក្រុមប្រឹក្សាសាលា (SAC) ដែលនឹងប្រព្រឹត្តទៅនៅ ខែកុម្ភៈ និង ខែមីនា ដើម្បីពិនិត្យមើល គម្រោងការកែលម្អសាលា និង ថវិកាបន្ថែមរបស់រដ្ឋសហព័ន្ធ។ លិខិតអញ្ជើញមាតាបិតា មកចូលរួមអង្គប្រជុំ នឹងផ្ញើទៅផ្ទះក្នុងរយៈពេលពីរសប្តាហ៍ជាប់ៗគ្នា ក្នុងខែកុម្ភៈ និង ម្តងទៀតនៅខែមីនា។ សាលានឹងដាក់សំបុត្រផ្ញើទៅនៅក្នុងក្របដាក់ ឯកសារសម្រាប់ការទាក់ទងរបស់សាលានៅថ្ងៃពុធ (Wednesday School Communication)។ សាលានឹងផ្ញើ អ៊ីមែល និង សារសម្លេងតាមទូរស័ព្ទ ទៅរំលឹកមាតាបិតា អំពីអង្គប្រជុំពិនិត្យមើលទិន្នន័យ។

៣. <u>**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា**</u> នឹងផ្តល់ ការសម្រួល ជំនួយបច្ចេកទេស និងជំនួយផ្សេងៗ ដែលចាំបាច់ដូចតទៅនេះ ដើម្បីជួយសាលាដែលទទួលជំនួយពីច្បាប់ Title I, Part A ក្នុងការរៀបចំគម្រោង និងការអនុវត្តន៍ សកម្មភាពនៃការចូលរួមរបស់មាតាបិតាដែលមានប្រសិទ្ធិភាព ដើម្បីបង្កើនជោគជ័យនៃការសិក្សា និងការអប់រំរបស់សាលា៖

- តាមការសហការជាមួយ អ្នកត្រួតពិនិត្យផ្នែកតម្រូវការនៃប្រាក់ជំនួយ អ្នកធ្វើទំនាក់ទំនងរវាងសហគមន៍និងសាលា ក្រុមប្រឹក្សាមាតាបិតានិងសាលានៃទីក្រុងហ្វីឡាដែលហ្វ្យា (PHSC) ក្រុមប្រឹក្សាមាតាបិតាផ្នែកច្បាប់ Title I ភ្នាក់ងារផ្នែកសិទ្ធិយល់ដឹងនៃការអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា សិទ្ធិអំណាចរបស់មាតាបិតា (PARENT POWER) និងក្រុមមាតាបិតាផ្សេងៗទៀត ផ្តល់សិក្ខាសាលាដល់សាលា អំពីការចូលរួមរបស់មាតាបិតា។
- ផ្តល់ការហ្វឹកហ្វឺនផ្នែកការងារ <u>ដោយ មាតាបិតា/អាណាព្យាបាល</u> ដល់នាយកសាលាថ្មី និងនាយកសាលាចាស់ និងរដ្ឋបាលដទៃទៀត អំពីវិធីអភិវឌ្ឍកិច្ចសន្យានៃការរួមសហការជាដៃគូជាមួយ មាតាបិតា/អាណាព្យាបាល។
- ហ្វឹកហ្វឺនបុគ្គលិក ថ្មី និងចាស់ អំពីភារៈកិច្ចនៃការចូលរួមរបស់មាតាបិតា (ឧ. អ្នកធ្វើទំនាក់ទំនងផ្នែកគាំទ្រការកែលម្អសាលា អ្នកធ្វើទំនាក់ទំនងរវាងសហគមន៍និងសាលា អ្នកសម្រួលការជាមួយសហគមន៍សាលា និងអ្នកជំនួយការខាងផ្តល់ឱវាទដែលចេះពីរភាសា) ដើម្បីជួយដល់សាលាក្នុងការអនុវត្តន៍នៃការចូលរួមរបស់មាតាបិតា។
- ត្រូវមានបុគ្គលិកប្រចាំ ការិយាល័យផ្នែកសមភាពអប់រំ ការិយាល័យផ្តល់ជំនួយផ្នែកបង្ហាត់បង្រៀនពិសេស និងបុគ្គលិកនៃការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ ដើម្បីផ្តល់ជំនួយបច្ចេកទេស។
- ការិយាល័យផ្នែក ធ្វើតាមតម្រូវការនៃប្រាក់ជំនួយ/Title I នឹងផ្តល់ជំនួយបច្ចេកទេសដល់សាលា និងអង្គការមាតាបិតា ដូចជា ក្រុមប្រឹក្សាមាតាបិតាផ្នែកច្បាប់ Title I (PAC), សមាគមមាតាបិតានិងសាលា ភ្នាក់ងារផ្នែកសិទ្ធិយល់ដឹងនៃការអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា សិទ្ធិអំណាចរបស់មាតាបិតា (PARENT POWER) និងក្រុមមាតាបិតាផ្សេងៗទៀត។
- ផ្តល់ការរៀបចំការហ្វឹកហ្វឺនផ្នែកការងារ តាមរយៈការិយាល័យផ្នែកការបង្ហាត់បង្រៀន និងការដឹកនាំ។
- ផ្តល់សិក្ខាសាលាដល់មាតាបិតាអំពី ការគាំទ្រដល់ជោគជ័យរបស់សិស្ស និងការចូលរួមរបស់មាតាបិតា។
- ផ្តល់ការហ្វឹកហ្វឺន និងព័ត៌មានផ្សេងៗ ដល់ ក្រុមប្រឹក្សាសាលា (SACs)។ នៅខែវិច្ឆិកា ២០១១ ក្រុមប្រឹក្សាសាលានីមួយៗនឹងមានផែនការអំពីវិធីដែលពួកគេរៀបចំធ្វើការជាមួយ មាតាបិតា Title I PREP ដើម្បីកំណត់ពេលហ្វឹកហ្វឺនមាតាបិតាដទៃទៀតដែលនៅសាលារបស់ពួកគេ។
- មាតាបិតា PREP ប្រចាំតំបន់ នឹងធ្វើជាទីប្រឹក្សារបស់ នាយកសាលា និងសមាជិកនៃក្រុមប្រឹក្សាសាលា ដើម្បីលើកឡើងនូវសេចក្តីត្រូវការរបស់សិស្ស និង មាតាបិតា នៅក្នុងផែនការដែលត្រូវអនុវត្ត និង ថវិកា Title I របស់សាលាពួកគាត់។
- ក្នុងការអនុលោមតាម ការគិតដល់ឆ្នាំ២០១៤ (Imagine 2014) សាលាជួយសម្រួលដល់ មាតាបិតា និងក្រុមគ្រួសារ ឲ្យមានលទ្ធភាពជួបជាមួយ គ្រូ និងនាយកសាលា។

៤. <u>សាលា George W. Childs</u> នឹងចាត់ចែង និងរួមបញ្ចូលផែនការនៃការចូលរួមរបស់មាតាបិតានៅក្នុងផ្នែក Part A ជាមួយនឹងផែនការនៃការចូលរួមរបស់មាតាបិតា តាមកម្មវិធីផ្សេងៗដូចតទៅ៖ បញ្ចូលកម្មវិធី ដូចជា៖ កម្មវិធី Head Start, Reading First, Early Reading First, Even Start, មាតាបិតាជាគ្រូបង្ហាត់បង្រៀន កម្មវិធីបង្ហាត់បង្រៀននៅផ្ទះសម្រាប់កុមារមុនថ្នាក់មត្តេយ្យ និងកម្មវិធីមុនថ្នាក់មត្តេយ្យដែលគ្រប់គ្រងដោយរដ្ឋ ដោយ៖

សាលានឹងអញ្ជើញមាតាបិតារបស់កម្មវិធី Head Start ឲ្យចូលរួមក្នុងសិក្ខាសាលាសម្រាប់មាតាបិតា និងក្នុងអង្គប្រជុំដែលពិនិត្យមើល ទិន្នន័យ និងច្បាប់ស្តីពីការចូលរួមរបស់មាតាបិតា ណាមួយក៏បាន។

រៀងរាល់ខែឧសភា កម្មវិធីថ្នាក់មត្តេយ្យមានការបើកឲ្យដើរមើលសាលា ហើយអញ្ជើញក្រុមគ្រួសាររបស់កម្មវិធី Head Start ទាំងអស់ឲ្យចូលរួម។ សិស្សរបស់កម្មវិធី Head Start មានអាទិភាពចុះឈ្មោះក្នុងកម្មវិធីថ្នាក់មត្តេយ្យមុនគេ។

ការដើរមើលសាលាសម្រាប់សិស្សថ្នាក់មត្តេយ្យ នឹងប្រព្រឹត្តិទៅនៅពាក់កណ្តាលខែឧសភា នៅក្នុងបន្ទប់ IMC។

៥. <u>សាលា George W. Childs</u> នឹងមានសកម្មភាពដូចតទៅ ដើម្បីធ្វើការវាយតម្លៃ ការចូលរួមរបស់មាតាបិតា ការវាយតម្លៃប្រចាំឆ្នាំ អំពីសកម្មភាព និងប្រសិទ្ធិភាព នៃច្បាប់នៃការចូលរួមរបស់មាតាបិតា ក្នុងការបង្កើនគុណភាពនៃកម្មវិធី របស់ច្បាប់ Title I, Part A។ ការវាយតម្លៃនឹងមានរួមបញ្ចូលទាំងការរកឃើញឧបសគ្គដែលរារាំងមិនឲ្យមាតាបិតាអាចចូលរួមបានច្រើន (ជាពិសេសចំពោះមាតាបិតាដែល ក្រខ្សត់ ពិការភាព ចេះភាសាអង់គ្លេសតិចតួច ចេះអក្សរតិចតួច ឬជាសាសន៍ ឬជនជាតិភាគតិច)។ សាលានឹងប្រើលទ្ធផលដែលបានពីការវាយតម្លៃអំពីច្បាប់នៃការចូលរួមរបស់មាតាបិតា និងសកម្មភាពផ្សេងៗ ដើម្បីរៀបចំផែនការនៃការចូលរួមរបស់មាតាបិតាឲ្យកាន់តែមានប្រសិទ្ធិភាព និងដើម្បីធ្វើការកែសម្រួលច្បាប់នៃការចូលរួមរបស់មាតាបិតា បើសិនជាចាំបាច់ (ដោយមានការចូលរួមពីសំណាក់មាតាបិតា)។

នាយកសាលានឹងចែកជូនការស្ទង់មតិទៅមាតាបិតាតាមរយៈក្របដាក់ឯកសារទាក់ទង នៅសប្តាហ៍ទីពីរនៃខែកុម្ភៈ។ ការស្ទង់មតិនឹងជួយដោះស្រាយនូវការព្រួយបារម្ភរបស់មាតាបិតា។ សាលានឹងសុំឲ្យអ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីរភាសា ជួយមាតាបិតាដែលមិនចេះភាសាអង់គ្លេស ដើម្បីធ្វើយ៉ាងណាឲ្យសាលាធ្វើតាមសេចក្តីត្រូវការរបស់ពួកគាត់។ នៅក្នុងអង្គប្រជុំនៅខែកុម្ភៈ និងខែមីនា សាលានឹងសុំឲ្យមាតាបិតាជួយផ្តល់យោបល់អំពីសេចក្តីត្រូវការក្នុងការកែលម្អ។

៦. <u>សាលា George W. Childs</u> នឹងពង្រីកទំហំនៃការចូលរួមរបស់មាតាបិតានៅសាលាឲ្យបានកាន់តែខ្លាំងឡើង ដើម្បីធ្វើយ៉ាងណាឲ្យមានប្រសិទ្ធិភាពដល់ការចូលរួមរបស់មាតាបិតា និងដើម្បីជួយដល់សម្ព័ន្ធភាពរវាងសាលា មាតាបិតា ហើយនិងសហគមន៍ ដើម្បីកែលម្អការសិក្សារបស់សិស្ស តាមរយៈសកម្មភាពដែលនឹងរៀបរាប់ដូចតទៅ៖

ក. <u>សាលា George W. Childs</u> ដោយមានការជ្រោមជ្រែងពីក្រសួងអប់រំ នឹងផ្តល់ជំនួយដល់មាតាបិតា តាមលក្ខណៈសមរម្យ ក្នុងការយល់ដឹងប្រធានបទដូចខាងក្រោមនេះ ដោយទទួលខុសត្រូវនូវសកម្មភាពដែលបានរៀបរាប់នៅក្នុងវគ្គនេះ --

- មុខវិទ្យាសិក្សាតាមខ្នាតគំរូរបស់រដ្ឋ
- ជោគជ័យក្នុងការសិក្សារបស់សិស្សតាមខ្នាតគំរូរបស់រដ្ឋ
- ការវាយតម្លៃរបស់រដ្ឋ និងរបស់តំបន់ រួមទាំងការវាយតម្លៃតាមវិធីផ្សេងៗទៀត
- តម្រូវការរបស់ច្បាប់ Title I, Part A
- វិធីតាមដានការរីកចម្រើនរបស់ក្មេង និង
- វិធីធ្វើការជាមួយអ្នកអប់រំ

នៅថ្ងៃទី៣០ ខែកញ្ញា ២០១៥ នាយកសាលាបានពន្យល់មាតាបិតាអំពី ច្បាប់ Title I, Part A នៅពេលជួបប្រជុំជាមួយបុគ្គលិកសាលានៅយប់ដំបូង តាមរយៈការបង្ហាញ powerpoint។ នៅពេលប្រជុំ ក្រុមប្រឹក្សាសាលា នាយកសាលានឹងពន្យល់ដល់សហគមន៍សាលាពីវិធីដែលសាលាចង់ធ្វើឲ្យបានតាមគំរូជោគជ័យនៃការសិក្សារបស់សិស្ស។ នៅពេលប្រជុំចែករបាយការណ៍ពិន្ទុនៅខែ ធ្នូ កុម្ភៈ និងខែ ឧសភា នាយកសាលា អ្នកទំនាក់ទំនងផ្នែកអប់រំពិសេស អ្នកផ្តល់ឱវាទ និងអ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីរភាសា អាចជួបជាមួយមាតាបិតា និងណែនាំពួកគាត់ពីវិធីនៃការសហការជាមួយគ្រូ និងការតាមដាននូវការរីកចម្រើនរបស់កូនពួកគាត់។

ខ. ដោយមានជំនួយពីក្រសួងអប់រំ <u>សាលា George W. Childs</u> នឹងផ្តល់សម្ភារៈ និងការហ្វឹកហ្វឺនផ្សេងៗ ដើម្បីជួយដល់មាតាបិតាក្នុងការជួយកូនរបស់ពួកគាត់ ដើម្បីបង្កើនជោគជ័យក្នុងការសិក្សា ដូចជាបង្កើតការហ្វឹកហ្វឺនផ្នែកអក្សរសាស្រ្ត និងការប្រើបច្ចេកវិទ្យា តាមលក្ខណៈសមរម្យ ជំរុញឲ្យមាតាបិតាចូលរួម ដោយ៖

ប្រើថវិការបស់ Title I សម្រាប់ការចូលរួមរបស់មាតាបិតា ទិញសៀវភៅឲ្យមាតាបិតា ដើម្បីបង្កើនចំណេះដឹងផ្នែក គណិតវិទ្យា និងអក្សរសាស្រ្ត។
រៀបចំសិក្ខាសាលាអំពីអក្សរសាស្រ្ត។
ឲ្យក្រុម City Year ធ្វើសិក្ខាសាលាក្រោយម៉ោងសិក្សា អំពីបច្ចេកវិទ្យាសម្រាប់មាតាបិតា។

គ. ដោយមានជំនួយពីក្រសួងអប់រំ <u>សាលា George W. Childs</u> នឹងអប់រំ គ្រូ បុគ្គលិកដែលបម្រើសិស្ស នាយកសាលា និងបុគ្គលិកដទៃទៀតពីវិធីទាក់ទងទៅ ប្រាស្រ័យទាក់ទងជាមួយ និង ធ្វើការជាមួយមាតាបិតា ដែលជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា ការឲ្យតម្លៃដល់យោបល់របស់មាតាបិតា និងអំពីវិធីអនុវត្ត និងការចាត់ចែងកម្មវិធីសម្រាប់មាតាបិតា ព្រមទាំងការបង្កើតចំណងមិត្តភាពរវាងមាតាបិតា និងសាលា ដោយ៖

គ្រូទាក់ទងទៅមាតាបិតា និងរកមាតាបិតាឲ្យជួយប្រចាំគ្រប់ថ្នាក់នីមួយៗ។
គ្រូសុំឲ្យមាតាបិតាចុះឈ្មោះក្នុងបញ្ជីទទួល អ៊ីមែល និង សារតាមទូរស័ព្ទដៃ ពីសាលា។
គ្រូសរសេរឈ្មោះអ្នកដែលពួកគាត់បានទាក់ទងទាំងអស់នៅក្នុងឯកសារ Google doc ដែលអាចចែកចាយដល់បុគ្គលិកទាំងអស់។
នៅពេលមានការហ្វឹកហ្វឺនផ្នែកការងារនៅខែវិច្ឆិកា បុគ្គលិកនឹងទទួលការហ្វឹងហ្វឺនពីវិធីសាស្រ្តនៃការទាក់ទងជាមួយមាតាបិតាដែលមានប្រសិទ្ធិភាព និងវិធីដ៏ល្អបំផុតដែលអាចជួយដល់ពួកគាត់។

ឃ. <u>សាលា George W. Childs</u> តាមតែអាចធ្វើទៅបាន និងតាមលក្ខណៈសមរម្យ នឹងរៀបចំ និង បញ្ចូល កម្មវិធីចូលរួមរបស់មាតាបិតា និងសកម្មភាពផ្សេងៗ ជាមួយកម្មវិធីមុនថ្នាក់មត្តេយ្យ (Head Start) កម្មវិធី Reading First, Early Reading First, Even Start, កម្មវិធីបង្ហាត់បង្រៀននៅផ្ទះ សម្រាប់កុមារមុនថ្នាក់មត្តេយ្យ កម្មវិធីមាតាបិតាជាគ្រូ ថ្នាក់មុនមត្តេយ្យរបស់រដ្ឋ និងកម្មវិធីផ្សេងៗទៀត និងបង្កើតសកម្មភាពផ្សេងៗ ដូចជា មណ្ឌលផ្តល់ជំនួយដល់មាតាបិតា ដែលជួយជំរុញ និងជួយមាតាបិតាឲ្យចូលរួមកាន់តែច្រើនក្នុងការអប់រំរបស់កូន ដោយ៖

មានតុ និងក្តារប្រកាសដំណឹង ដែលបានរៀបចំទុកក្នុងបន្ទប់ប្រជុំ ដែលស្ថិតនៅក្រៅការិយាល័យសាលា ដែលមានអក្សរសាស្រ្ត និងព័ត៌មានសម្រាប់មាតាបិតា។ គេបានរៀបចំតុមួយថែមទៀតនៅរបៀងសាលាជាន់ក្រោម ដើម្បីឲ្យមាតាបិតាអាចប្រមូលព័ត៌មាន និងយកសៀវភៅដែលឥតគិតប្រាក់ នៅពេលពួកគាត់មកទទួលកូនពីសាលា និងពីកម្មវិធី Head Start។

ង. <u>សាលា George W. Childs</u> នឹងធ្វើសកម្មភាពដូចតទៅនេះ ដើម្បីធ្វើយ៉ាងណាឲ្យមានការផ្ញើជូនដល់មាតាបិតានូវព័ត៌មានដែលទាក់ទងនឹងសាលា និង កម្មវិធីសម្រាប់មាតាបិតា អង្គប្រជុំ និងសកម្មភាពផ្សេងៗ តាមលក្ខណៈងាយស្រួលយល់ និងជាទម្រង់តែមួយ ព្រមទាំង ទម្រង់ផ្សេងៗទៀតទៅតាមសេចក្តីស្នើសុំ និងតាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយប្រើភាសាដែលមាតាបិតាអាចយល់បាន៖

សាលា Childs មាន អ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីរភាសាចំនួនបួននាក់ ដែលបកប្រែប្រតិទិនប្រចាំខែ ដែលសាលាផ្ញើទៅផ្ទះ។ ពួកគេក៏ចម្លងឯកសាររបស់ក្រសួង ឲ្យទៅមាតាបិតា ទៅតាមភាសារបស់ពួកគាត់ ហើយប្រគល់ឲ្យសិស្សយកទៅផ្ទះ។ ហើយពួកគេក៏អាចជួបជាមួយមាតាបិតានៅពេលប្រជុំចែករបាយការណ៍ពិន្ទុ និងនៅពេលណាដែលមាតាបិតាត្រូវការជំនួយផ្នែកបកប្រែភាសា។ សាលាក៏មានជំនួយបកប្រែភាសាតាមទូរស័ព្ទ តាមរយៈក្រុមហ៊ុន Pacific Telephonic Interpretation service នៅពេលណាមាតាបិតាត្រូវការជំនួយបកប្រែភាសាភ្លាមៗ និងនៅពេលដែលអ្នកជំនួយការផ្នែកផ្តល់ឱវាទដែលចេះពីរភាសា មិនអាចជួយបាន។

## <u>ផ្នែកទី៣</u> <u>សមាសភាគរបស់ច្បាប់នៃការចូលរួមរបស់មាតាបិតាទូទាំងសាលា</u>

**<u>កំណត់សំគាល់៖</u>** ច្បាប់ស្តីពីការចូលរួមសកម្មភាពសាលារបស់មាតា អាចបញ្ចូលវគ្គបន្ថែម និងការរៀបរាប់អំពីសកម្មភាពតាមការសម្រេចផ្សេងទៀត តាមការពិគ្រោះជាមួយមាតាបិតា ដែលសាលាជ្រើសរើសដើម្បីអនុវត្តការបង្កើនចំនួននៃការចូលរួមរបស់មាតាបិតានៅសាលា និង ប្រព័ន្ធរបស់សាលា ដើម្បីជួយដល់ជោគជ័យក្នុងការសិក្សារបស់ក្មេង ដូចជាសកម្មភាពដ៏ទៃទៀតដែលនឹងរៀបរាប់ ក្រោមមាត្រាលេខ ១១១៨(e) នៃច្បាប់ ESEA៖

- ឲ្យមាតាបិតាចូលរួមក្នុងការរៀបចំការហ្វឹកហ្វឺន គ្រូ នាយកសាលា និងអ្នកអប់រំផ្សេងៗទៀត ដើម្បីបង្កើនប្រសិទ្ធិភាពនៃការហ្វឹកហ្វឺននេះ
- ផ្តល់ការហ្វឹកហ្វឺនផ្នែកអក្សរសាស្រ្តដែលចាំបាច់ដល់មាតាបិតា ដោយប្រើប្រាក់ជំនួយពី Title I, Part A បើសិនជាក្រសួងអប់រំអស់ប្រាក់ជំនួយដទៃទៀត សម្រាប់ការហ្វឹកហ្វឺននោះ។
- បង់ថ្លៃឲ្យបានសមរម្យ និងចាំបាច់ ទៅលើការចាយវាយផ្សេងៗ ដែលទាក់ទងទៅនឹងការចូលរួមរបស់មាតាបិតា រួមទាំងការដឹកនាំ ដើម្បីឲ្យមាតាបិតាមានលទ្ធភាពចូលរួមក្នុងអង្គប្រជុំរបស់សាលា និងការហ្វឹកហ្វឺនផ្សេងៗទៀត
- ហ្វឹកហ្វឺនមាតាបិតា ដើម្បីឲ្យជួយបង្កើនការចូលរួមពីមាតាបិតាផ្សេងទៀត
- រៀបចំអង្គប្រជុំនៅសាលាតាមពេលវេលាខុសៗគ្នា ឬជួបប្រជុំនៅផ្ទះរវាង គ្រូ ឬអ្នកអប់រំដទៃទៀត ដែលធ្វើការផ្ទាល់ជាមួយក្មេងដែលចូលរួមជាមួយមាតាបិតាដែលមិនអាចចូលរួមប្រជុំនៅសាលាបាន ដើម្បីបង្កើនការចូលរួមឲ្យកាន់តែច្រើនពីមាតាបិតាក្នុងការអប់រំរបស់កូន។
- អនុម័ត និង អនុវត្តន៍ តាមគំរូណាដែលអាចជួយកែលម្អដល់ការចូលរួមរបស់មាតាបិតា។
- បង្កើតក្រុមប្រឹក្សាមាតាបិតាទូទាំងក្រសួង ដើម្បីផ្តល់យោបល់ចំពោះបញ្ហា ដែលទាក់ទងនឹងការចូលរួមរបស់មាតាបិតា ក្នុងកម្មវិធីរបស់ច្បាប់ Title I, Part A។
- បង្កើតតួនាទីសមរម្យ សម្រាប់អង្គការនៅក្នុងសហគមន៍ និងពាណិជ្ជកម្មផ្សេងៗ រួមទាំង អង្គការសាសនា ក្នុងសកម្មភាពនៃការចូលរួមរបស់មាតាបិតា និង
- ផ្តល់ជំនួយសមរម្យផ្សេងៗ ដល់សកម្មភាពនៃការចូលរួមរបស់មាតាបិតា តាមមាត្រាលេខ ១១១៨ តាមការស្នើសុំរបស់មាតាបិតា។

* * * * *

## <u>ផ្នែកទី៤</u>    <u>សេចក្តីអនុម័ត</u>

ច្បាប់នៃការចូលរួមរបស់មាតាបិតានៅសាលា <u>George W. Childs</u> នេះ បានបង្កើតឡើងរួមគ្នាជាមួយ និងមានការយល់ព្រមពីមាតាបិតា ដែលមានភស្តុតាងនៅក្នុងទំព័រចុះហត្ថលេខា របៀបវារៈ និងលិខិតផ្សព្វផ្សាយដំណឹង។

សាលានឹងចែកជូនច្បាប់នេះទៅមាតាបិតាទាំងអស់ នៅថ្ងៃ ឬ មុនថ្ងៃ ទី២០ ខែតុលា ឆ្នាំ២០១៥__________________ ។

_______________________________________

*(ហត្ថលេខា របស់នាយកសាលា/Signature of Principal)*

_______________________________________

*(ថ្ងៃខែ/Date)*